# ដំណឹងជ្រើសរើសបុគ្គលិក

**ចំរើន** ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាឈានមុខគេផ្នែកសង្គម ដែលប្រតិបត្តិប្រកបដោយទំនួលខុសត្រូវ ដើម្បីនិរន្តរភាពនៃការវិវឌ្ឍន៍ជាវិជ្ជមានដល់ជីវភាពគ្រួសារក្រីក្រសកម្ម តាមរយៈការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងសេវាសេដ្ឋកិច្ចសង្គម។ ចំរើន កំពុងឈរនៅលំដាប់ថ្នាក់ទី១១ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ក្នុងប្រទេសកម្ពុជា ក្នុងន័យចំនួនដៃគូប្រាក់កម្ចីសកម្ម និងតំបន់ប្រតិបត្តិការ ដែលមានសាខាជាង ២៥ ការិយាល័យ នៅក្នុង ១៦ ខេត្ត-រាជ ធានី។ បច្ចុប្បន្ននេះ ចំរើន ត្រូវការជ្រើសរើសបុគ្គលិកដូចខាងក្រោម៖

| មុខតំណែង | រាយការណ៍ជូន | ទីតាំង | ឈប់ទទួលពាក្យ |
|---|---|---|---|
| មន្ត្រីឥណទាន (២០ នាក់) | ប្រធានសាខា | សាខាខេត្តកំពង់ស្ពឺ កំពត កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ធំ កំពង់ចាម តាកែវ ក្រចេះ ព្រៃវែង បន្ទាយមានជ័យ ត្បូងឃ្មុំ បាត់ដំបង សៀមរាប និង រាជធានីភ្នំពេញ មោងឬស្សី | ២០ កុម្ភៈ ២០១៧ |

## ភារកិច្ច និង ការទទួលខុសត្រូវ

- ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវផលិតផល និងសេវាកម្មរបស់គ្រឹះស្ថានចំរើន ដើម្បីទាក់ទាញដៃគូសក្តានុពលទៅតាមតំបន់គោលដៅ
- សម្របសម្រួលដំណើរការនៃការបញ្ចេញឥណទាន
- សម្របសម្រួលការងារដទៃទៀតតាមការចាត់ចែងរបស់អ្នកគ្រប់គ្រងផ្ទាល់ ក្នុងក្របខណ្ឌគ្រឹះស្ថានចំរើន

## គុណវុឌ្ឍិ

- ត្រូវមានចំណេះដឹងទូទៅយ៉ាងហោចណាស់ត្រូវបានបញ្ចប់ថ្នាក់ទី១២ និងមានអទិភាពសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រគ្រប់ជំនាញ
- មានចំណេះដឹងដូចជា៖ លេខនព្វន្ត និងការកត់ត្រាឱ្យមានភាពត្រឹមត្រូវ ភាសាអង់គ្លេស ដែលអាចអានស្តាប់ និងសរសេរបានខ្លះៗ
- មានប្រវត្តិ និងអត្តចរិតល្អ មានភាពស្មោះត្រង់ ម៉ឺងម៉ាត់ សុភាពរាបសារ មានសុជីវធម៌ល្អ និងមានឆន្ទៈក្នុងការធ្វើការងារជាមួយប្រជាជនក្រីក្រនៅតាមសហគមន៍
- មានប្រាស្រ័យទាក់ទងល្អ ចូលចិត្តធ្វើការងារជាក្រុម ជាមនុស្សឧស្សាហ៍ព្យាយាម និងមានការប្តេជ្ញាចិត្តខ្ពស់ចំពោះការងារ
- ចេះបើកបរម៉ូតូយ៉ាងស្ទាត់ជំនាញ

## អត្ថប្រយោជន៍

**ចំរើន** ផ្តល់ជូននូវប្រាក់បៀវត្សរ៍សមរម្យ ប្រាក់ឧបត្ថម្ភទឹកចិត្តប្រចាំខែ ឱកាសដំឡើងតួនាទី ប្រាក់ឧបត្ថម្ភជួលម៉ូតូ ថ្លៃសាំង កាតទូរស័ព្ទ អត្ថប្រយោជន៍ចំពោះសុខភាព ការធានារ៉ាប់រងគ្រោះថ្នាក់២៤ម៉ោង ប្រាក់រង្វាន់ប្រចាំឆ្នាំ ការបណ្តុះបណ្តាលអំពីជំនាញ ការរៀនសូត្រអំពីការអនុវត្តន៍ការងារជាក់ស្តែង និងលិខិតបញ្ជាក់អំពីបទពិសោធន៍ការងារ

## របៀបនៃការដាក់ពាក្យ

**បេក្ខជន-បេក្ខនារី** ដែលមានចំណាប់អារម្មណ៍ និងមានគុណវុឌ្ឍិដូចខាងលើ សូមផ្ញើប្រវត្តិរូបសង្ខេប (CV & Cover letter) មានបិទរូបថតថ្មីភ្ជាប់ជាមួយនឹងការថតចម្លង លិខិតបញ្ជាក់ការងារ (បើមាន) សៀវភៅគ្រួសារ សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ ប័ណ្ណបើកបរ រួចផ្ញើមកកាន់ស្នាក់ការចំរើនដែលនៅជិតលោកអ្នក ឬការិយាល័យកណ្តាលដែលមានអាសយដ្ឋាន៖ ផ្ទះលេខ៤២៥ ផ្លូវ២៧១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា អ៊ីមែល: job@chamroeun.com

**ចំរើន** ផ្តល់នូវឱកាសស្មើភាពគ្នាក្នុងការប្រកួតប្រជែង ស្ត្រី និងជនពិការត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ មានតែបេក្ខជនដែលជាប់ក្នុងបញ្ជីសម្រាំងប៉ុណ្ណោះនឹងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍ រាល់ប្រវត្តិរូប និងឯកសារផ្សេងៗដែលបានដាក់មិនត្រូវបានប្រគល់ត្រលប់វិញឡើយ។